ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ 036 សលណ.ធទឧ

## សេចក្តីជូនដំណឹងបន្ថែម

## ស្តីពី ស្ថានភាពសីតុណ្ហភាពអប្បបរមា នៅព្រះរាជាណាចក្រកម្ពុជា

បន្ទាប់ពីបានធ្វើការតាមដាន និងព្យាករណ៍លើស្ថានភាពអាកាសធាតុរួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងបន្ថែមដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសាធារណជនឱ្យបានជ្រាបថា ៖ នៅចុងរដូវរំហើយនេះ ( ចាប់ពីថ្ងៃទី 15 ដល់ថ្ងៃទី 20 ខែមករា ឆ្នាំ 2014 ) ស្ថានភាពសីតុណ្ហភាពអប្បបរមា នៅព្រះរាជាណាចក្រកម្ពុជា នឹងមានការធ្លាក់ចុះម្តងទៀត ។ តាមការព្យាករណ៍សីតុណ្ហភាពអប្បបរមា នៅតាមបណ្តារាជធានី-ខេត្តមួយចំនួននឹងមានស្ថានភាព ដូចខាងក្រោម ៖

- ខេត្តព្រះវិហារ ឧត្តរមានជ័យ រតនគិរី និងខេត្តមណ្ឌលគិរី សីតុណ្ហភាពអប្បបរមាអាចនឹងចុះដល់ 12-14 $^{0}$C
- ខេត្តបាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ សៀមរាប ក្រចេះ និងខេត្តស្ទឹងត្រែង សីតុណ្ហភាពអប្បបរមាអាចនឹងចុះដល់ 16-18 $^{0}$C
- រាជធានីភ្នំពេញ ខេត្តកំពង់ធំ កំពង់ចាម ព្រៃវែង ស្វាយរៀង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តកណ្តាល សីតុណ្ហភាពអប្បបរមាអាចនឹងចុះដល់ 18-20 $^{0}$C ។

ចំពោះខេត្តកោះកុង ព្រះសីហនុ កំពត និងខេត្តកែប សីតុណ្ហភាពអប្បបរមានឹងស្ថិតក្នុងរង្វង់ពី 22-25 $^{0}$C ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន **ពិសេសចំពោះវីរៈកងទ័ពដែលកំពុងឈរជើងតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ** និងសូមបង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្ន ចំពោះស្ថានភាពអាកាសធាតុ ដែលចុះត្រជាក់ជាថ្មីម្តងទៀតនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី 09 ខែមករា ឆ្នាំ ២០១៤

**រដ្ឋមន្ត្រី**

លឹម_គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh